# សហជីពសេរីកម្មករនៃព្រះរាជាណាចក្រកម្ពុជា

**FREE TRADE UNION OF WORKERS OF THE KINGDOM OF CAMBODIA**

អាស័យដ្ឋានៈ ផ្ទះលេខ១៣B, ផ្លូវ២៤០, សង្កាត់ជ័យជំនះ, ខណ្ឌដូនពេញ, រាជធានីភ្នំពេញ, ព្រះរាជាណាចក្រកម្ពុជា

Address: House #13B, Street 240, Phnom Penh, Kingdom of Cambodia.

Tel: (855-12) 805 310, (855-23) 217 015 / Fax: (855-23) 217 015 / E-mail: CAMFTU@bigpond.com.kh


**"យុត្តិធម៌សង្គម ជាគ្រឹះនៃសន្តិភាព"**

**"Soicial justice is the foundation for peace"**

Protest Pernas Company who stopped workers

# ការទាមទាររបស់កម្មករ-កម្មការិនីរោងចក្រកាត់ដេរដឺណាស់

ដោយបានឃើញ **"សេចក្តីជូនដំណឹងកាត់បន្ថយកម្មករ"** វេនយប់របស់នាយកក្រុមហ៊ុន **ដឺណាស់** (PERNAS) ចុះថ្ងៃទី១២ ខែឧសភា ឆ្នាំ១៩៩៨ ។

កម្មករ-កម្មការិនី **ដឺណាស់** ទាំងអស់ទាមទារឲ្យនាយកក្រុមហ៊ុនផ្តល់ប្រាក់ឈ្នួលចំនួន៣ខែ គឺស្មើនឹង ១២០ដុល្លារ ជូនកម្មករ-កម្មការិនីវេនយប់ ប្រសិនបើក្រុមហ៊ុនចង់កាត់បន្ថយកម្មករទាំង៧០០នាក់ បើពុំនោះទេកម្មករវេនថ្ងៃទាំងអស់នឹងរួបរួមគ្នា ធ្វើកូដកម្មមិនធ្វើការងារ រហូតមានដំណោះស្រាយសមរម្យ ត្រូវបានភាគីទាំងពីរព្រមព្រៀងគ្នា ។

ប្រការដែលក្រុមហ៊ុនបានត្អូញត្អែរ អំពីការខាតបង់ ហើយជួបការលំបាកផ្នែកហិរញ្ញវត្ថុ និងការទិញសំលៀកបំពាក់ពីបរទេសមានការថយចុះយ៉ាងខ្លាំងស្ទើរស្ទានមិនដល់នោះ គ្មាននរណាអាចជឿបានទេ បើគ្មានស្ពងការគណនេយ្យ ជាន់ខ្ពស់ឯករាជ្យ និងអ្នកជំនាញការសេដ្ឋកិច្ច ពាណិជ្ជកម្ម ឯករាជ្យមួយអះអាងបញ្ជាក់ថាពិត ។ ក្រុមហ៊ុនភាគច្រើនតែង ត្អូញត្អែរ អំពីការខាតបង់ ប៉ុន្តែគេសង្កេតឃើញថា ឧស្សាហកម្មរោងចក្រកាត់ដេរកំពុងតែរីកដុះដាល នៅកម្ពុជាគួរឲ្យកត់ សំគាល់ ក្រោយព្រឹត្តិការណ៍ថ្ងៃទី៥-៦ ខែកក្កដា ឆ្នាំ១៩៩៧ ។

មាត្រាទី៧៤នៃច្បាប់ការងារបានបញ្ជាក់យ៉ាងច្បាស់ថា... គ្មានការបញ្ឈប់ណាមួយអាចធ្វើទៅបានដោយគ្មានហេតុផលសមរម្យ ទាក់ទងនឹងសម្បទា ឬចរិយានៃនិយោជិត យោលទៅលើភាពចាំបាច់នៃដំណើររបស់សហគ្រាស របស់គ្រឹះស្ថាន ឬរបស់ក្រុមហ៊ុនឡើយ ។

យើងយល់ឃើញថាការបញ្ឈប់កម្មករ និយោជិតទាំងអស់កំពុងស្ថិតក្នុងល្បិចអ្វីម្យ៉ាងឬអាថ៌កំបាំងអ្វីមួយរបស់ថៅកែ ។

កម្មករ-កម្មការិនីជាង២០០០នាក់នៃរោងចក្រ **ដឺណាស់** (PERNAS) អាចមានអធ្យាស្រ័យខ្លះ ចំពោះនាយកក្រុមហ៊ុន ប្រសិនបើពិនិត្យឃើញថា រោងចក្រចាស់ទ្រុឌទ្រោមត្រូវរុះរើជួសជុលជាថ្មី ឬក៏រោងចក្ររងនូវគ្រោះមហន្តរាយពីធម្មជាតិ ប៉ុន្តែការបញ្ឈប់កម្មករនៅពេលនេះ គឺជាល្បិចកលសុទ្ធសាធរបស់នាយកក្រុមហ៊ុន ក្នុងការព្យាយាម ព្យាបាទកម្មករ ដោយសារពួកយើងងើបឡើងរំដោះខ្លួនពីការជិះជាន់ មិនគោរពច្បាប់ការងាររបស់ថៅកែ ។

ដូច្នេះសូមកម្មករ-កម្មការិនីទាំងអស់ ( **វេនយប់និងវេនថ្ងៃ** ) រួបរួមគ្នាជួយដោះស្រាយទុក្ខធុរៈកម្មករវេនយប់ ដែលកំពុងរងគ្រោះពីការបញ្ឈប់ការងារនេះ ។

ភ្នំពេញ ថ្ងៃទី១៣ ខែឧសភា ឆ្នាំ១៩៩៨

សហជីពសេរីកម្មករនៃព្រះរាជាណាចក្រកម្ពុជា
ស.ស.ក.ព.ក
F.T.U.W.K.C
FREE TRADE UNION OF WORKERS OF THE KINGDOM OF CAMBODIA